វាមិនមែនកើតឡើងត្រឹមតែលើផ្លូវកាយនោះទេ! វារាប់បញ្ចូលទាំងការធ្វើបាបផ្លូវចិត្ត និងផ្លូវសេដ្ឋកិច្ច។

វាក៏មិនមែនកើតឡើងតែលើស្ត្រី ឬក្មេងស្រីនោះដែរ វាអាចកើតចំពោះបុរស ឬក្មេងប្រុសដូចគ្នា។

ស្វែងរកជំនួយ និងទទួលយកការពិភាក្សា ប្រសិនបើអ្នកជួបប្រទះ និងគិតថាកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ តាមរយៈ

-អ្នកពិគ្រោះយោបល់ផ្នែកផ្លូវចិត្ត និងផ្នែកច្បាប់
-សមត្ថកិច្ច
-លោកគ្រូ អ្នកគ្រូ ឬសាស្ត្រាចារ្យ
-គ្រួសារ មិត្តភក្តិ ឬបុគ្គលដែលអ្នកទុកចិត្តបំផុត







សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS


# ហិង្សាយេនឌ័រ

វាជាអ្វី? ហេតុអ្វីបានខ្ញុំត្រូវតែដឹងអំពីវា?



# ហិង្សាយេនឌ័រ

**ហិង្សាយេនឌ័រ** គឺជាការធ្វើបាប សំដៅទៅលើទម្រង់នៃការបង្ខិតបង្ខំ និង ការត្រួតត្រាទៅលើផ្លូវចិត្ត ផ្លូវកាយ និង សេដ្ឋកិច្ច ដែលអាចនឹងប៉ះពាល់ដល់មនុស្សគ្រប់រូប ដោយសារការទាក់ទងគ្នា និងផ្នត់គំនិតដែលមាននៅក្នុងសង្គម។ ការឲ្យតម្លៃតែមនុស្សប្រុសថាជាបុគ្គលសំខាន់ ហើយគិតថាមនុស្សស្រីសមហ្នឹងទទួលរងនូវការធ្វើបាប និងការដាក់កំហិត។ ការមើលរំលងពីរឿងរ៉ាវដែលកើតមានក្នុងសង្គម ដោយគិតថាក្នុងនាមជាមនុស្សប្រុស ទោះត្រូវគេធ្វើបាប វាយដំ ជេរប្រមាថ ក៏វាមិនជាបញ្ហា។ គំនិតទាំងអស់នេះ គឺជារបាំងដល់ការជួយសង្គ្រោះជនរងគ្រោះទាំងឡាយដែលរងគ្រោះដោយសារអំពើហិង្សា។



## មានដឹងអត់?

យោងតាមការស្រាវជ្រាវរបស់អង្គសហប្រជាជាតិ ប្រជាជនកម្ពុជាប្រមាណ ៧០% នៃផ្ទៃប្រទេស ធ្លាប់ទទួលរងការធ្វើបាប និងជាប់ស្រមោលអន្តកាលពីអំពើហិង្សាទាំងនោះ។

# តើអំពើហិង្សា វាមានរូបភាពបែបណាខ្លះ?

### អំពើហិង្សាផ្លូវកាយ

សកម្មភាពទាំងឡាយណាដែលធ្វើអោយប៉ះពាល់ដល់រូបរាងកាយទោះមាន ស្នាម ឬ អត់មានស្នាមដូចជាការវាយនឹងដំបង។ ការប្រើប្រាស់កម្លាំងបាយ ធ្វើបាប វាយដំទៅលើបុគ្គលណាម្នាក់  ឬ ការបំពានលើរាងកាយក្នុងនៃមិនសមស្របណាមួយ អាចចាត់ទុកថាជាអំពើហិង្សាផ្លូវកាយ។ វា អាចជាសកម្មភាពធ្វើឲ្យប៉ះពាល់ដល់ផ្លូវភេទ តាមរយៈការរំលោភផ្លូវភេទការធ្វើអាស្រូវ អាសអាភាស ការបៀតបៀនកេរខ្មាស ដូចជាការបង្ខំរួមភេទជាមួយប្រពន្ធការបង្ហាញរូបភាពអាសអាភាស។



### អំពើហិង្សាផ្លូវចិត្ត

ជាការធ្វើទុក្ខទោសដល់អារម្មណ៍ ឬ សកម្មភាពទាំងឡាយណាដែលធ្វើអោយប៉ះពាល់ផ្លូវចិត្តរបស់គេ ហើយមិនអាចទទួលយកបាន ដូចជាការប្រើពាក្យសំដីជេរប្រមាថ គំរាមគំហែង បំបិតសិទ្ធិសេរីភាព។

### អំពើហិង្សាផ្លូវសេដ្ឋកិច្ច

ជាសកម្មភាពបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បិទសិទ្ធិក្នុងការប្រើប្រាស់ រកប្រាក់ចំណូលនិង ចូលរួមចាត់ចែងទ្រព្យសម្បត្តិរួមមានដូចជា លេងល្បែង ប្រើប្រាស់គ្រឿងញៀន បោកចានឆ្នាំង លួចលក់ម៉ូតូ ឬ មិនឲ្យទៅ ធ្វើការរក ប្រាក់ចំណូល។

# ACTION

## ការកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍

- និយាយពន្យល់ពីផលប៉ះពាល់នៃអំពើហិង្សាដោយបើកចំហជាមួយមិត្តភក្តិ ឪពុកម្តាយនិង សហគមន៍
- ធ្វើការដោយផ្ទាល់ជាមួយសហគមន៍ដើម្បីផ្លាស់ប្តូរឥរិយាបថហិង្សានិងការពារមនុស្សគ្រប់គ្នាក្នុងសហគមន៍
- ស្វះស្វែងរកវិធីសាស្ត្រដោះស្រាយដោយអហិង្សា
- លើកទឹកចិត្តយុវវ័យអោយចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក។
- ជំរុញឲ្យមានការសិក្សាលើជំនាញសិទ្ធ និងច្បាប់

